គណៈកម្មាធិការដើម្បីសិទ្ធិបោះឆ្នោតរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេស

**COMMITTEE FOR ELECTION RIGHTS OF OVERSEAS CAMBODIANS (THE CEROC)**

**Email: board@khmeroversea.info, www.khmeroversea.info**

# សេចក្តីថ្លែងការណ៍

ព្រះសង្ឃគ្រប់ព្រះអង្គនិងជនរួមជាតិជាទីគោរព

**កម្មវត្ថុ៖** លក្ខណ្ឌថ្មីតម្រូវអោយអ្នកចុះឈ្មោះបោះឆ្នោតត្រូវស្នាក់នៅអាស័យដ្ឋានបច្ចុប្បន្ន៣០ថ្ងៃឡើងទៅដែលប្រកាសដោយក្រសួងមហាផ្ទៃនៅថ្ងៃ១៤សីហាឆ្នាំ២០១៧បន្ថែមទៅលើសេចក្តីប្រកាសខែធ្នូឆ្នាំ២០១៥ គឺរំលោភលើច្បាប់បោះឆ្នោតដែលបានកំណត់អោយមានតែសាក្សីម្នាក់ដើម្បីបញ្ជាក់លំនៅដ្ឋានហើយអាចចុះឈ្មោះបោះឆ្នោតបាន។

គណៈកម្មាធិការដើម្បីសិទ្ធិបោះឆ្នោតរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេសហៅកាត់ថាស៊ីរ៉ក់ មានការខកចិត្តជាខ្លាំងចំពោះសេចក្តីប្រកាសរបស់ក្រសួងមហាផ្ទៃដែលមានដែនសមត្ថកិច្ចទៅលើយុត្តាធិការរបស់គជបក្នុងការកំណត់សុពលភាពអ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតដែលបានតម្រូវអោយមានតែសា-ក្សីម្នាក់ដើម្បីកំណត់លំនៅឋានបច្ចុប្បន្នក្នុងការចុះឈ្មោះបោះឆ្នោតបាន។

ការតម្រូវអោយស្នាក់នៅ៣០ថ្ងៃនិងត្រូវមានលិខិតបញ្ជាក់ពីនាយប៉ុស្តិ៍នគរបាលគឺផ្ទុយស្រឡះពីច្បាប់បោះឆ្នោត និងអាចមើលឃើញថាជាការរំលោភទៅលើដែនសមត្ថកិច្ចរបស់គជប។ យើងខ្ញុំសូមបដិសេធន៍នូវមតិរបស់លោកសោម សូរីដា ដែលជាលេខាធិការរងរបស់គជបក្នុងការទទួលស្គាល់ប្រកាសរបស់ក្រសួងមហាផ្ទៃតាមរយៈវេទិការអ្នកស្តាប់អាស៊ីសេរីកាលពីថ្ងៃទី២២ខែសីហាឆ្នាំ២០១៧ តាមឆន្ទានុសិទ្ធិនិងឋានៈរបស់លោក លោកមិនអាចមានសិទ្ធិអារកាត់អ្វីឡើយលុះត្រាតែមានសេចក្តីសំរេចពីសមាជិកទាំង៩របស់គជប។

**សំណូមពរ៖** យើងខ្ញុំសំណូមពរអោយគជបពិចារណានិរាករសេចក្តីប្រកាសរបស់ក្រសួងមហាផ្ទៃដើម្បីអនុវត្តន៍តាមច្បាប់បោះឆ្នោតអោយបានត្រឹមត្រូវ ធានានូវឯករាជ្យភាពមិនលំអៀង និងវិជ្ជាជីវៈរបស់ខ្លួនជាពិសេសអាចសំរួលភាពងាយស្រួលអោយកម្មករក្នុងស្រុកនិងចំណាកស្រុកយើងរាប់លាននាក់អាចមានសិទ្ធិចុះឈ្មោះបានដោយគ្មានឧបសគ្គរឿងរស់នៅអោយគ្រប់៣០ថ្ងៃ។

***សូមព្រះសង្ឃគ្រប់ព្រះអង្គនិងជនរួមជាតិទទួលនូវពុទ្ធពរទាំងឡាយ៤ប្រការកុំបីអាក់ខានឡើយ។***

ធ្វើនៅប្រទេសកាណាដា ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧

**សេង សុភ័ណ**

ប្រធានគណៈកម្មាធិការដើម្បីសិទ្ធិបោះឆ្នោតរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេស

Committee for Election Rights of Overseas Cambodians (The CEROC)
Contact: 6596 Marlborough Ave., Burnaby, BC, V5H 3M1, Canada
Tel: 604-428-4385, Fax: 604-620-3433